ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៤ សសរ

# សេចក្តីសម្រេច

## ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ទទួល និង ពិភាក្សាការងារជាមួយគណៈប្រតិភូថ្នាក់ដឹកនាំ នៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសអោយប្រើច្បាប់បង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល .

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

# សំរេច

**ប្រការ១ :** បង្កើតគណៈកម្មការអន្តរក្រសួងមួយដើម្បីទទួល និងពិភាក្សាការងារជាមួយគណៈប្រតិភូជាន់ខ្ពស់ នៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ដឹកនាំដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី Thongloun SISOULITH ដែលនឹងអញ្ជើញមកបំពេញទស្សនៈកិច្ចជាផ្លូវការ និងជាមិត្តភាព នៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី ២ ដល់ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០០២ រួមមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ស៊ុយ សែម | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ប្រធាន |
| ២-ឯកឧត្តម | សុខ ស៊ីផាន់ណា | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣-ឯកឧត្តម | អ៊ិត ប្រាំង | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៤-ឯកឧត្តម | ឡៅ ម៉ុនហឺន | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៥-ឯកឧត្តម | ខ្លូត រ៉ាន់ឌី | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៦-លោក | តាន់ គឹមទិន់ | អគ្គនាយកអគ្គិសនីកម្ពុជា | សមាជិក |
| ៧-លោក | ឌុន សារ៉េន | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ថាមពលក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៨-លោក | ពេជ ឫទ្ធី | អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តរជាតិ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩-លោក | សុខ សុភ័ក្ត្រ | ប្រធាននាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០-លោក | អ៊ុយ សុខារក្ខ | ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេសក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១១-លោក | ទ៉ែ សុវណ្ណា | ប្រធានការិយាល័យ នៃនាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ ក្រសួងពាណិជ្ជកម្ម | សមាជិក |

**ប្រការ២ :** គណៈកម្មការនេះមានភារកិច្ច ពិភាក្សាលើបញ្ហាពីរគឺ :

១-ការតភ្ជាប់ និងការលក់ថាមពលអគ្គិសនីអោយកម្ពុជា

២-កិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្ម រវាងប្រទេសទាំងពីរកម្ពុជា-ឡាវ ។

**ប្រការ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងផែនការ និងឯកឧត្តម អស់លោក ដែលមានរាយនាម ក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចប្រការ ៣

-ឯកសារ-កាលប្បវត្តិ